**អនុក្រឹត្យលេខ ១៦ អនក្រ . បក**
**ស្តីពីការផ្ទេរឥណទាន**

******

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៥ / ៩៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ នស / ៩៣ / ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៧ ចុះថ្ងៃទី ៣១ ខែ ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែក ឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧

-បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីចំណាត់ថ្នាក់ ចំណូលនិងចំណាយថវិកាតាមប្រភេទជំពូកប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៤ និងប្រកាសស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៥ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ២៣ ខែ មករា ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ លេខ ៣៣៦ ប្រក.សហវ .ថ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៦ និង លេខ ៩០១ សហវ.ថ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

www.pheakdeylaw.com

**សំរេច**

មាត្រា ១ ._ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទាន ពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១.៦០១.១០០.០០០រៀល ( មួយពាន់ ប្រាំមួយរយមួយលាន មួយរយពាន់រៀលគត់ ) មកជំពូក ៣១ ក្នុងវង់ ថវិកា របស់ក្រសួងការពារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ២ ._ ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ចំណាយលើរបបសោធិនពិការ មុនបញ្ជូនទៅក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ហើយក្រសួងការពារជាតិត្រូវកាត់បន្ថយចំនួនទ័ពតាមចំនួនសោធិនពិការដែលបានបញ្ជូនទៅក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

មាត្រា ៣ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី ១ សម្តេចនាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និងត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៧២ អនក្រ . តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

******

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៥ / ៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ និង ព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល

-បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៨៩៧ /១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

www.pheakdeylaw.com